# ព័ត៌មានលម្អិតដែលអ្នកត្រូវដឹងមុនពេលសិក្សា

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

| ខគម្ពីរដែលត្រូវសិក្សា | ព័ត៌មានលម្អិតដែលអ្នកត្រូវដឹងមុននឹងសិក្សាខគម្ពីរទាំងនេះ |
|---|---|
| កិច្ចការ ១:២៣–២៦ | ពួកសាវក និងអ្នកដើរតាមព្រះគ្រីស្ទផ្សេងទៀតបានប្រមូលផ្ដុំគ្នា ដើម្បីពិភាក្សាថា តើអ្នកណានឹងជំនួស យូដាស អ៊ីស្ការីយ៉ុត ជាសាវកម្នាក់ក្នុងចំណោមសាវកដប់ពីរនាក់ ។ |
| កិច្ចការ ២:៣៧–៤៣ | ខណៈដែលពួកសាវកត្រូវបានប្រមូលផ្ដុំគ្នានៅក្រុងយេរូសាឡិម មិនយូរប៉ុន្មានបន្ទាប់ពីការយាងឡើងទៅកាន់ស្ថានសួគ៌របស់ព្រះគ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើពួកគេម្នាក់ៗតាមរបៀបដ៏មានឥទ្ធិពល ( សូមមើល កិច្ចការ ២:១–៨ ) ។ ដោយពោរពេញទៅដោយព្រះវិញ្ញាណ នោះពេត្រុសបានធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ( សូមមើល កិច្ចការ ២:១៤–៣៦ ) ។ វគ្គបទគម្ពីរនេះពិពណ៌នាអំពីឥទ្ធិពលនៃការចាក់ស្រោចខាងវិញ្ញាណទៅលើបណ្ដាជនជាច្រើន ដែលបានធ្វើជាសាក្សីអំពីវា ។ |
| កិច្ចការ ៣:១–៨; ៤:៨–១០ | ពេត្រុស និងយ៉ូហានបានជួបបុរសពិការម្នាក់នៅព្រះវិហារបរិសុទ្ធក្នុងក្រុងយេរូសាឡិម ។ |
| កិច្ចការ ៥:១២–១៦ | កាលពីមុន សាវកទាំងឡាយបានទទួលការព្រមានមកពីអ្នកដឹកនាំសាសន៍យូដាថា កុំឲ្យនិយាយអំពីព្រះយេស៊ូវគ្រីស្ទទៀតឡើយ ( សូមមើល កិច្ចការ ៤:១៣–១៨ ) ។ |
| កិច្ចការ ៥:១៧–២៥ | ពេត្រុស និងយ៉ូហានត្រូវបានគេចាប់ដាក់គុក បន្ទាប់ពីបានបន្លឺថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្ហាញអព្ភូតហេតុក្នុងព្រះនាមទ្រង់ ។ |

- តើអ្នកបានរៀនអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទពីខគម្ពីរទាំងនេះ ដែលជះឥទ្ធិពលដល់សេចក្ដីជំនឿ និងការទុកចិត្តរបស់អ្នកលើទ្រង់ ?
- តើព្រឹត្តិការណ៍ទាំងនេះបង្ហាញថា ព្រះអង្គសង្គ្រោះកំពុងដឹកនាំសាសនាចក្ររបស់ទ្រង់តាមរយៈសាវករបស់ទ្រង់យ៉ាងដូចម្ដេច ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *Details You Need to Know before Study* ។ Cambodian ។
PD60012661 258. Printed in the United States of America.